ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ០៦/២១ ក.ធ.ស.សណ្ណ

# សេចក្ដីណែនាំ

## ស្ដីពី

## ការផ្អាកពិធីសាសនា ការជួបជុំ និងកម្មវិធីផ្សេងៗបែបសាសនា ដើម្បីបង្ការ ទប់ស្កាត់ ការរីករាលដាល នៃជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ

**យោង** ៖ -ច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

-អនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្ដីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

-អនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១។

ដោយសារស្ថានភាពនៃការចម្លងក្នុងសហគមន៍ នៃព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ នៅតែបន្តមិនទាន់ធូរស្រាល និងដើម្បីចៀសវាងការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ចូលទៅក្នុងសហគមន៍ទ្រង់ទ្រាយធំ តាមរយៈពិធីសាសនា ការជួបជុំ និងកម្មវិធីជួបជុំផ្សេងៗបែបសាសនា ក្រសួងធម្មការ និងសាសនា សូមធ្វើការណែនាំដល់ថ្នាក់ដឹកនាំសាសនា និងបណ្ដាអង្គភាពនានាចំណុះឱ្យក្រសួងទាំងអស់អនុវត្តនូវ វិធានការបន្ទាន់ដូចខាងក្រោម៖

១-ត្រូវផ្អាកជាបណ្ដោះអាសន្ននូវរាល់ការរៀបចំពិធីសាសនា ការជួបជុំ និងកម្មវិធីជួបជុំផ្សេងៗបែបសាសនា ។

២-បន្តរឹតបន្តឹងការប្រុងប្រយ័ត្ន និងពង្រឹងការអនុវត្តវិធានការពារ «៣ការពារ និង៣កុំ» ឱ្យបានម៉ឺងម៉ាត់។

៣-ត្រូវរក្សាគម្លាតសុវត្ថិភាពសង្គមឱ្យបានខ្ជាប់ខ្ជួនក្នុងចន្លោះយ៉ាងតិច១,៥ ម៉ែត្រ។

៤-ត្រូវពាក់ម៉ាស វាស់កម្ដៅ សម្អាតដៃនឹងសាប៊ូ អាល់កុល ឬជែល ជាប្រចាំ។

៥-ករណីមានការសង្ស័យ សូមទាក់ទងបន្ទាន់ទៅអាជ្ញាធរមូលដ្ឋានដែលនៅជិតបំផុត ឬ ទំនាក់ទំនងលេខ Hotline ១១៥។

៦-គណៈសង្ឃទាំងពីរគណៈ និងថ្នាក់ដឹកនាំគ្រប់សាសនា ព្រះមេត្តា-មេត្តាសហការផ្ដល់ព័ត៌មានពាក់ព័ន្ធជំងឺកូវីដ-១៩ មកក្រសួង តាមរយៈមន្ទីរធម្មការ និងសាសនារាជធានី-ខេត្ត។

៧-ត្រូវអនុវត្តវិធានការច្បាប់ដែលមានជាធរមាន ចំពោះជនណាដែលបំពានការណែនាំ និងមិនសហការជាមួយនឹងអាជ្ញាធរមូលដ្ឋាន ក្នុងការងារទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

ទទួលបានសេចក្ដីណែនាំនេះ សូមថ្នាក់ដឹកនាំសាសនា និងបណ្ដាអង្គភាពនានាចំណុះឱ្យក្រសួងទាំងអស់ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងចូលរួមសហការអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ពុធ ៤ កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០២១
**រដ្ឋមន្ត្រី**

ឈិត_សុខុន

**ចម្លងជូន-ជូន**
-សម្ដេចព្រះអគ្គមហាសង្ឃរាជទាំងពីរគណៈ
-សម្ដេចព្រះសង្ឃនាយកទាំងពីរគណៈ
-ក្រសួងសុខាភិបាល
-ខុទ្ទកាល័យឯកឧត្ដមរដ្ឋមន្ត្រី
«ដើម្បីថ្វាយ-ជូនជ្រាប»
-គ្រប់អង្គភាពក្រោមឱវាទក្រសួង
- គ្រប់សាសនាទាំងអស់
«ដើម្បីផ្សព្វផ្សាយ-អនុវត្ត»
-ឯកសារ-កាលប្បវត្តិ